គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
The National Committee for Sub-National Democratic Development



# សន្និសីទជាតិស្តីពី
# កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖
# " មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត "

**ថ្ងៃ៧-៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៨**
**រាជធានីភ្នំពេញ៖ មជ្ឈមណ្ឌលសន្និបាតកោះពេជ្រ**

## ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

1



## ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម

- ✓ <u>ការបញ្ជ្រាបយេនឌ័រ៖</u> ការយកចិត្តទុកដាក់ ក្នុងការកាត់បន្ថយគម្លាតរវាងបុរសនិងស្ត្រី ដែលកើតឡើងតាមរយៈផ្នត់គំនិតរបស់សង្គម។
- ✓ <u>បរិយាប័ន្ន ៖</u> ការដាក់បញ្ចូលនិងគិតគូរដល់គ្រប់ក្រុមគោលដៅទាំងអស់ក្នុងសង្គម
- ✓ <u>សមធម៌សង្គម៖</u> វិធានការនានា ដើម្បីឈានទៅកាត់បន្ថយគម្លាត នៃការទទួលបានអត្ថប្រយោជន៍ក្នុងសង្គម។

*ការបញ្ជ្រាបយេនឌ័រក្នុងបរិបទសមធម៌សង្គម និងបរិយាប័ន្ន* ជាការគិតគូរនិងការដោះស្រាយនូវបញ្ហា កង្វល់ និងតម្រូវការរបស់ស្ត្រី និងបុរស កុមារា កុមារី ដែលស្ថិតក្រុមមនុស្សគ្រប់ប្រភេទ មានដូចជាក្រុមពិការ ក្រុមជនជាតិដើមភាគតិច ។ល។

ដើម្បីឈានទៅសម្រេចបាននូវសមភាពរបស់ជនគ្រប់រូប ទាំងបុរស ទាំងស្ត្រី ក្នុងការចូលរួម ការទទួលផល ការគ្រប់គ្រង និងធ្វើសេចក្តីសម្រេច ។

2

## យើងទាំងអស់គ្នា មិនទុកអ្នកណាម្នាក់ឱ្យនៅឯកកោរ

*"Leaving No One Behind"*

គឺជាហេតុផលចម្បងរបស់រាជរដ្ឋាភិបាល ក្នុងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ
បានកំណត់ និងមានបំណងឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ សម្រេចនូវលទ្ធផលជាក់លាក់
ក្នុងការលើកស្ទួយគុណភាព នៃជីវិតរស់នៅប្រជាពលរដ្ឋមូលដ្ឋាន
**ដោយចាប់ផ្តើមពីជនក្រីក្រ និងជនងាយរងគ្រោះ ។**



www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមបានគិតគូរ និងឆ្លើយតប ក្នុងច្បាប់ គោលនយោបាយ នីតិវិធី និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ

- កំណត់បញ្ញត្តិនានា **លើកកម្ពស់ការចូលរួមស្ត្រី** សំដៅដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ច មូលដ្ឋានរបស់ខ្លួន ប្រកបដោយសមធម៌
- **អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ**គ្រប់ឃុំសង្កាត់ និង**គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ**ឃុំ សង្កាត់
- **ស្ត្រីម្នាក់យ៉ាងតិច** ក្នុងថ្នាក់ដឹកនាំភូមិ និងការចូលរួមក្នុងដំណើរការរៀបចំផែនការ និងថវិកាឃុំ សង្កាត់

### ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- កំណត់គោលការណ៍សំខាន់ៗសម្រាប់ផ្តល់ការណែនាំតម្រង់ទិស ធានាឱ្យប្រជាពលរដ្ឋ **ជាពិសេស ស្ត្រី ជនពិការ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ** អាចចូលរួមនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

### ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋាន

- ធានាលើកកម្ពស់សមភាពយេនឌ័រ ទាំងក្នុងការតែងតាំងគ្រប់គ្រងបុគ្គលិក ផែនការអភិវឌ្ឍន៍ ថវិកា ព្រមទាំងការបង្កើតយន្តការ និងនីតិវិធី **ដើម្បីឆ្លើយតបស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ**
- បង្កើត និងដំណើរការ**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារីនិងកុមារ**
- **ការបង្កើនសមាសភាពស្ត្រី** នៅក្នុងគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា



www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមបានគិតគូរ និងឆ្លើយតប ក្នុងច្បាប់ គោលនយោបាយ នីតិវិធី និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កម្មវិធីជាតិរយៈពេល១០ឆ្នាំ




- ផ្តោតការបញ្ជ្រាបយេនឌ័រជាអន្តរវិស័យ តាមគោលការណ៍សមភាព និងសមធម៌យេនឌ័រ។
- ដោះស្រាយបញ្ហាវិសមភាពយេនឌ័រ នៅក្នុងមូលដ្ឋាន និងសហគមន៍
- ការបញ្ជ្រាបយេឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ទាំងក្នុងកម្រិតបុគ្គល និងកម្រិតស្ថាប័ន
- ជាមូលដ្ឋានគ្រឹះ ក្នុងការតាក់តែងផែនការអនុវត្ត នៃកម្មវិធី



www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## ផែនការអនុវត្តរបស់កម្មវិធីជាតិ

| ដំណាក់កាលទី១ ៖ ២០១១-២០១៤ | ដំណាក់កាលទី២ ៖ ២០១៥-២០១៧ | ដំណាក់កាលទី៣៖ ២០១៨-២០២០ |
|---|---|---|
| កំណត់នូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី យ៉ាងជាក់លាក់ ក្នុងប្រព័ន្ធគ្រប់គ្រង កិច្ចដំណើរការកសាងផែនការ ការរៀបចំថវិកា នីតិវិធីអនុវត្តការងារ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ | ត្រូវយកចិត្តទុកដាក់ពង្រឹងបរិយាប័ន្ន និងសមធម៌សង្គម ព្រមទាំងវាស់វែងដោយសូចនាករ។ វគ្គកាតព្វកិច្ចស្តីពីបរិយាប័ន្ន និងសមធម៌សង្គមសម្រាប់ថ្នាក់ដឹកនាំ។ បន្តយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនស្ត្រី នៅក្នុងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | បន្តលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម ត្រូវការបញ្ជ្រាបក្នុងលទ្ធផលរំពឹងទុកពាក់ព័ន្ធនានានៃសមាសភាគទាំង៥ អនុវត្តផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងតំណែងគ្រប់គ្រង បន្តវគ្គកាតព្វកិច្ច និងរៀបចំប្រព័ន្ធតាមដាន និងផ្លាស់ប្តូរមេរៀនបទពិសោធន៍ |

➢ ការបញ្ជ្រាបយេនឌ័រ នៅតែបន្តយកចិត្តទុកដាក់ និងឆ្លើយតបនៅក្នុងលិខិតបទដ្ឋានគតិយុត្តនានា



www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# កិច្ចការថ្មីៗ និងទិសដៅបន្ត

**ផែនការយុទ្ធសាស្ត្រ ស្តីពី "ការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ"** ត្រូវបាន អនុម័ត នាខែមេសា ឆ្នាំ២០១៧ កំណត់៖

- ***២០% នៃនាយក នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលារាជធានី ខេត្ត ជាស្ត្រី ។***
- ***២៥% នៃនាយក នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលាក្រុង ស្រុក ខណ្ឌ ជាស្ត្រី ។***

***បន្តជំរុញអនុវត្តផែនការយុទ្ធសាស្ត្រ***

ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសំរាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានផ្សេងៗ បាន ឆ្លើយតបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម

7

ការបង្ខិតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# ស្ថិតិស្ត្រី ក្នុងមុខតំណែងសំខាន់ៗ

- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ជាស្ត្រី៩,៨៩% អាណត្តិទី១ និង**កើនដល់១៣,២៣%** នៅអាណត្តិទី២
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាស្ត្រី១២,៦៨% អាណត្តិទី១ និង**កើនដល់១៣,៨៥%** នៅអាណត្តិទី២
- អភិបាល នៃគណៈអភិបាលខេត្ត ជាស្ត្រី **ចំនួន០១រូប**
- ស្ត្រី ជាអភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត **ចំនួន២៦រូប**
- ស្ត្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក **ចំនួន៧រូប**
- ស្ត្រី ជាអភិបាលរង នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ **ចំនួន១៩៤រូប**

8

ការបង្ខិតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## អំពីសេចក្តីសន្និដ្ឋាន

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកម្មវិធីមួយដែលបានចាត់ទុកបញ្ហាយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម គឺជាបន្តអន្តរវិស័យ ដោយមានប្រព័ន្ធយន្តការអនុវត្ត និងជំរុញការអនុវត្ត ។
- ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងនីតិវិធី និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម គឺជាការវិនិយោគដ៏មានតម្លៃ និងប្រកបដោយគ្រប់ជ្រុងជ្រោយសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ ។

មានន័យថា ធនធានមនុស្ស និងគ្រប់សមាសភាពនៃកិច្ចអភិវឌ្ឍន៍ទាំងអស់ ត្រូវបានយកមកគិតគូរ យកចិត្តទុកដាក់ និងឆ្លើយតប ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ត្រឡប់មកវិញកាន់តែប្រសើរជាងមុន សម្រាប់គ្រួសារ ស្ថាប័ន និងសហគមន៍របស់ខ្លួន ។

9

ការបង្ខិតរដ្ឋបាលទៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/







# សូមអរគុណ...!

info@mowa.gov.kh
www.mowa.gov.kh
mowa.gov.kh

ផ្លូវត្រុងមាន់ ភូមិដំណាក់ធំ៣
សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា